ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ:.....១៣.....អយក.សណន

សេចក្តីណែនាំប្រតិបត្តិ
ស្តីពី
ការបំប៉នបន្ថែមដល់សិស្សរៀនយឺត នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ

ដើម្បីធានាបានថា សិស្សរៀនយឺតមានមូលដ្ឋានសមស្របសម្រាប់ការបន្តការសិក្សានៅថ្នាក់បន្ទាប់ទៀត ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់សាលារៀន ស្តីពីការបំប៉នបន្ថែមដល់សិស្សរៀនយឺត នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដូចខាងក្រោម៖

១- ការធ្វើតេស្តវាយតម្លៃសមត្ថភាពសិស្ស

- **គោលបំណង៖** ដើម្បីវាយតម្លៃសមត្ថភាពសិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ព្រមទាំងជួយគ្រូបង្រៀនឱ្យវាយតម្លៃបានត្រឹមត្រូវ និងកំណត់បាននូវខ្លឹមសារមេរៀនដែលសិស្សរៀនយឺត។
- **ពេលវេលា៖** ប្រចាំខែនីមួយៗ។
- **សិស្សគោលដៅ៖** សិស្សានុសិស្សទាំងអស់ពីថ្នាក់ទី២ ដល់ទី៦
- **គណៈគ្រប់គ្រង និងគ្រូបង្រៀនត្រូវ៖**
  - គណៈគ្រប់គ្រង ត្រូវដឹកនាំនិងគ្រប់គ្រងលើការងារតេស្តរង្វាយតម្លៃសមត្ថភាពសិស្ស
  - គ្រូបង្រៀនរៀបចំផលិតតេស្តសិស្ស លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ឬប្រើប្រាស់ឧបករណ៍ វាយតម្លៃដើម្បីធ្វើការវិនិច្ឆ័យបញ្ហាសិស្ស ដែលបង្កើតឡើងដោយក្រសួង (កញ្ចប់ឯកសារទី១ ស្តីពីការបំប៉នបន្ថែម ជូនភ្ជាប់)
  - គ្រូបង្រៀនដឹកនាំធ្វើតេស្តសិស្សទៅតាមគោលការណ៍នៃការប្រឡង
  - គ្រូបង្រៀនកែកិច្ចការសិស្ស និងបញ្ចូលពិន្ទុក្នុងកុំព្យូទ័រ ឬ បញ្ជីលទ្ធផលតេស្ត
  - គ្រូបង្រៀនរៀបចំបញ្ជីឈ្មោះសិស្សរៀនយឺត ដោយបញ្ជាក់ខ្លឹមសារមេរៀនដែលរៀនយឺតទាំងមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ដោយមានការឯកភាពពីគណៈគ្រប់គ្រងសាលា
  - គ្រូបង្រៀនរៀបចំផែនការរំលស់សិស្សរៀនយឺតប្រចាំខែ និងប្រចាំត្រីមាស ដោយមានការឯកភាពពីគណៈគ្រប់គ្រងសាលា។

២- វិធីសាស្ត្របំប៉នបន្ថែមដល់សិស្សរៀនយឺត

ផ្អែកតាមខ្លឹមសារមេរៀនដែលសិស្សម្នាក់ៗរៀនយឺត និងតាមផែនការរំលស់សិស្សរៀនយឺត លោកគ្រូ អ្នកគ្រូ ត្រូវអនុវត្តការបង្រៀននិងរៀនតាមវិធីសាស្ត្រដូចខាងក្រោម៖

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- ផលិតឯកសារបំប៉នបន្ថែមដល់សិស្សរៀនយឺត ឬប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែមដែលផលិតដោយក្រសួង ទៅតាមខ្លឹមសារមេរៀនដែលពួកគេត្រូវការបំពេញបន្ថែម និង/ឬ ប្រើប្រាស់វីដេអូការបង្រៀន និងសន្លឹកកិច្ចការដែលក្រសួងបានផលិត និងផ្តល់ជូនកន្លងមក ជាជំនួយបន្ថែម
- ប្រើប្រាស់ឯកសារបំប៉នបន្ថែមបន្តបន្ទាប់ដែលផលិតដោយក្រសួងដើម្បីជួយបំប៉នសិស្សរៀនយឺត
- ជួយសិស្សរៀនយឺតស្របពេល ដោយគ្រូរៀបចំឱ្យសិស្សរៀនយឺតអង្គុយនៅជិតសិស្សដែលអាចជួយពួកគេបាន ហើយគ្រូបង្រៀនត្រូវឧស្សាហ៍ទៅជួយ មើល សួរ និងណែនាំជាប្រចាំ
- ជួយសិស្សរៀនយឺតនៅចុងម៉ោង ដោយចំណាយពេល ១០ ទៅ១៥នាទី ដើម្បីបង្រៀនបន្ថែម
- ជួយសិស្សរៀនយឺតនៅថ្ងៃព្រហស្បតិ៍សប្តាហ៍ទី១ ទី២ និងទី៣ ដោយអនុញ្ញាតឱ្យតែសិស្សរៀនយឺតតែប៉ុណ្ណោះមកចូលរួមបំប៉ន
- ប្រជុំពិភាក្សាជាមួយគណៈគ្រប់គ្រងសាលា និងគណៈកម្មការគ្រប់គ្រង/ទ្រទ្រង់សាលារៀនដើម្បីពិនិត្យ
- លទ្ធភាពដោះស្រាយថវិកាឧបត្ថម្ភគ្រូបង្រៀនដែលស្ម័គ្រចិត្តជួយបង្រៀនសិស្សរៀនយឺត ក្រៅម៉ោងសិក្សា
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ជូនគណៈគ្រប់គ្រងសាលារៀន។

៣- តួនាទីភារកិច្ច របស់អ្នកពាក់ព័ន្ធ

៣.១- នាយកដ្ឋានបឋមសិក្សា

- សម្របសម្រួលជាមួយអង្គការដៃគូ និងនាយកដ្ឋានពាក់ព័ន្ធរៀបចំសេចក្តីណែនាំស្តីពីការបំប៉នបន្ថែមដល់សិស្សរៀនយឺត ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេច
- ផលិតសម្ភារៈ ឯកសារ វីដេអូការបង្រៀន និងសន្លឹកកិច្ចការ ដើម្បីជួយដល់សិស្សរៀនយឺត
- ផ្តល់សម្ភារៈ ឯកសារ វីដេអូការបង្រៀន និងសន្លឹកកិច្ចការ ទៅសាលារៀនតាមរយៈក្រុមតេលេក្រាម គេហទំព័រផ្លូវការរបស់ក្រសួង និងបណ្តាញទំនាក់ទំនងសង្គមជនៃទៀត
- ផ្តល់ការណែនាំបន្ថែម ដល់អ្នកអនុវត្តនៅពេលត្រូវការ
- ពិនិត្យតាមដានការអនុវត្តកម្មវិធី នៅថ្នាក់ក្រោមជាតិ និងសាលារៀន
- បូកសរុបរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួង និងអ្នកពាក់ព័ន្ធ។

៣.២- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

- ផ្តល់សម្ភារៈ ឯកសារវីដេអូការបង្រៀន និងសន្លឹកកិច្ចការទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈក្រុមតេលេក្រាម និងមធ្យោបាយផ្សេងទៀត
- ផ្តល់ការណែនាំបន្ថែម ដល់អ្នកអនុវត្តនៅពេលត្រូវការ
- ពិនិត្យតាមដានការអនុវត្តកម្មវិធី នៅតាមសាលារៀន
- បូកសរុបរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូននាយកដ្ឋានបឋមសិក្សា។

៣.៣- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- ផ្តល់សម្ភារៈ ឯកសារ វីដេអូការបង្រៀន និងសន្លឹកកិច្ចការ ទៅសាលារៀន តាមរយៈក្រុមតេលេក្រាម
- ផ្តល់ការណែនាំបន្ថែម ដល់អ្នកអនុវត្តនៅពេលត្រូវការ
- ពិនិត្យតាមដានការអនុវត្តកម្មវិធី នៅតាមសាលារៀន
- បូកសរុបរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

៣.៤- គណៈគ្រប់គ្រងសាលារៀន

- ដឹកនាំការប្រជុំណែនាំបូកសរុបលទ្ធផលនៃវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ លើការអនុវត្តសកម្មភាព
- ជានាថាគ្រូបង្រៀនមានសេចក្តីណែនាំ សម្ភារៈ ឯកសារ វីដេអូការបង្រៀន និងសន្លឹកកិច្ចការ
- សម្របសម្រួលជាមួយគ្រូបង្រៀន ក្នុងការរៀបចំកាលវិភាគជួយសិស្សរៀនយឺត
- ផ្តល់ថវិកាថតចម្លងឯកសារជូនកុមារក្រីក្រ ងាយរងគ្រោះ និងបំផុសចលនាឱ្យមាតាបិតា អ្នកអាណាព្យាបាលសិស្សដែលមានលទ្ធភាព ឱ្យថតចម្លងសន្លឹកកិច្ចការនិងឯកសារដោយខ្លួនឯង
- ពិនិត្យលទ្ធភាពស្វែងរកឬវិភាជន៍ថវិកា ដើម្បីគាំទ្រដល់គ្រូបង្រៀនដែលបានស្ម័គ្រចិត្តជួយបំប៉នបន្ថែម
- ពិនិត្យតាមដានការអនុវត្ត និងជួយគ្រូបង្រៀនជាប់ជាប្រចាំ
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៣.៥- មាតាបិតា អ្នកអាណាព្យាបាលសិស្ស

- បង្កលក្ខណៈ និងលើកទឹកចិត្តកូន ដើម្បីឱ្យកូនដែលរៀនយឺតបានទទួលការបំប៉នបន្ថែមជាទៀងទាត់
- បន្តទំនាក់ទំនងជាមួយគ្រូបង្រៀន និងតាមដានលទ្ធផលនៃការសិក្សារបស់កូនជាប់ជាប្រចាំ
- ចូលរួមឧបត្ថម្ភជាថវិកា និងសម្ភារៈ ដើម្បីគាំទ្រដល់ដំណើរការបំប៉នបន្ថែម
- ជួយបង្រៀនកូនៗនៅផ្ទះ និងបង្កលក្ខណៈងាយស្រួលដល់កូនបានរៀន/បំប៉នបន្ថែម
- ចូលរួមប្រជុំតាមការអញ្ជើញរបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សា បុគ្គលិកអប់រំ អាជ្ញាធរដែនដី មាតាបិតាអ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២១
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

កន្លែងទទួលៈ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ឧទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី **"ដើម្បីជ្រាបជាព័ត៌មាន"**
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងអ្នកពាក់ព័ន្ធ **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានបឋមសិក្សា